ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៨ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារតម្រង់ទិសអាជីវកម្មបរិយាប័ន្ន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

**ប្រការ១ :** បង្កើតក្រុមការងារតម្រង់ទិសអាជីវកម្មបរិយាប័ន្ន ដែលសរសេរជាអក្សរកាត់ថា **ក.ត.អ.ប.** ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ហេង សុខគង់** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ប្រធាន |
| ២. ឯកឧត្តម | **ស៊ឹម ណារ៉ា** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. ឯកឧត្តម | **ទេព តិយ៉ោរិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តម | **ប្រាក់ ដាវីដ** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥.ឯកឧត្តម | **សំហោង បូរ៉ា** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៦.ឯកឧត្តម | **នុត អ៊ុនវ័ណារ៉ា** | អគ្គលេខាធិការរង នៃគណៈកម្មាធិការ<br>វិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៧.ឯកឧត្តម | **ណៅ ធូក** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់<br>និងនេសាទ | សមាជិក |
| ៨.ឯកឧត្តម | **ប៉ុញ សច្ចៈ** | រដ្ឋលេខាធិការក្រសួងធនធានទឹក<br>និងឧតុនិយម | សមាជិក |
| ៩.ឯកឧត្តម | **ផូ ផារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០.លោកជំទាវ | **គង់ សុរីតា** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ១១.ឯកឧត្តម | **ហ៊ីត ផេង** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហគ្រាស<br>ធុនតូចនិងមធ្យម និងសិប្បកម្ម<br>នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ<br>បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍ |
| ១២.ឯកឧត្តម | **ផល សុជាតិ** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន<br>គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ<br>ផលិតផលមួយ | សមាជិក |
| ១៣.ឯកឧត្តម | **ឃួន លីមឈាន់** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន<br>ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម<br>និងជនបទ | សមាជិក |
| ១៤.ឯកឧត្តម | **ជួរ ជេតធីចន្ទ** | ទីប្រឹក្សា និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋាន<br>កិច្ចការទូទៅ នៃក្រសួងឧស្សាហកម្ម<br>វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៥.ឯកឧត្តម | **ឌី សមស៊ីដេត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ<br>នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៦.លោក | **ទ៊ីន ធី** | អគ្គនាយករង នៃវិទ្យាស្ថានជាតិស្ថិតិ<br>នៃក្រសួងផែនការ | សមាជិក |
| ១៧.ឯកឧត្តម | **ម៉េង និមល** | អគ្គនាយករងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ១៨.ឯកឧត្តម | **សួង ណាយ** | អនុប្រធានសភាមុខរបរ និងមីក្រូសហគ្រាស<br>កម្ពុជា | សមាជិក |
| ១៩.លោក | **ប៊ុន សម្បត្តិ** | អគ្គលេខាធិការនៃសមាគមសហគ្រិន<br>វ័យក្មេងកម្ពុជា | សមាជិក |
| ២០.លោក | **តែ សឿផាន់** | អគ្គលេខាធិការរងនៃសម្ព័ន្ធសមាគម<br>សហគ្រាសធុនតូច និងមធ្យមកម្ពុជា | សមាជិក |
| ២១.លោកស្រី | **កែង បណ្ដាល** | ហេរញ្ញិក នៃសមាគមសហគ្រិនស្ត្រីកម្ពុជា | សមាជិក |
| ២២.លោក | **ហ៊ុន សាង** | ប្រធាននាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ<br>និងការងារអាស៊ាន នៃក្រសួងឧស្សាហកម្ម<br>វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក។ |

**ក.ត.អ.ប.** អាចមានសមាសភាពបន្ថែមទៀត តាមការចាំបាច់។

**ប្រការ២ :** ក្រុមការងារតម្រង់ទិសអាជីវកម្មបរិយាប័ន្ន មានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

- សម្រេចលើផែនការសកម្មភាពសម្រាប់ការជំរុញអាជីវកម្មបរិយាប័ន្ន
- បញ្ជ្រាបការយល់ដឹងនិងផ្សព្វផ្សាយអំពីអាជីវកម្មបរិយាប័ន្ន
- ផ្ដល់សេចក្ដីណែនាំយុទ្ធសាស្ត្រដល់ការជំរុញអាជីវកម្មបរិយាប័ន្ន
- ធានាប្រសិទ្ធភាព និងនិរន្តរភាពនៃដំណើការជំរុញអាជីវកម្មបរិយាប័ន្ន
- ពិនិត្យ និងសម្រេចផ្តល់ ឬដកហូតវិញ្ញាបនបត្រអាជីវកម្មបរិយាប័ន្នតាមសំណើរបស់គណៈកម្មការវាយតម្លៃទទួលស្គាល់អាជីវកម្មបរិយាប័ន្ន
- រៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាដើម្បីគ្រប់គ្រង និងជួយជំរុញអាជីវកម្មបរិយាប័ន្ន
- រៀបចំ និងសម្របសម្រួលការងារអាជីវកម្មបរិយាប័ន្នថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ
- ចូលរួម រៀបចំ និងសម្របសម្រួលកិច្ចប្រជុំកំពូលអាជីវកម្មបរិយាប័ន្នអាស៊ាន និងពានរង្វាន់អាជីវកម្មបរិយាប័ន្នអាស៊ាន
- ពិនិត្យ វាយតម្លៃ និងលើកយោបល់សុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើគម្រោងស្ដីពីអាជីវកម្មបរិយាប័ន្ន
- សហការជាមួយក្រសួង ស្ថាប័ននានា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិស័យឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីជំរុញ និងរៀបចំយន្តការលើកទឹកចិត្តក្រុមហ៊ុនអាជីវកម្មបរិយាប័ន្ន
- រៀបចំរបាយការណ៍ស្ដីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**ប្រការ៣ :** អនុប្រធាន និងសមាជិក **ក.ត.អ.ប.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំប្រជុំ។

**ក.ត.អ.ប.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬវិស័យឯកជនឱ្យចូលរួមប្រជុំពិភាក្សា ផ្តល់យោបល់ និងស្នើសុំសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខណ្ឌការងាររបស់ខ្លួន។

**ប្រការ៤ :** **ក.ត.អ.ប.** អាចមានអនុក្រុមការងារជំនាញមួយចំនួន ដែលកំណត់ដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ក.ត.អ.ប.** ត្រូវមានគណៈកម្មការវាយតម្លៃទទួលស្គាល់អាជីវកម្មបរិយាប័ន្ន និងលេខាធិការដ្ឋានមួយនៅក្នុងទីស្ដីការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលកំណត់ដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥ :** **ក.ត.អ.ប.** មានសិទ្ធិប្រើត្រាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅក្នុងកិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

**ប្រការ៦ :** **ក.ត.អ.ប.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិប្រចាំឆ្នាំស្ថិតក្នុងកញ្ចប់ថវិការបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ហិរញ្ញប្បទានឥតសំណង ជំនួយបច្ចេកទេស និងប្រភពស្របច្បាប់ផ្សេងៗទៀតសម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

**ប្រការ៧ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១០ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ